ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# កំណត់ហេតុ

## កិច្ចប្រជុំកម្រិតបច្ចេកទេស លើសេចក្តីព្រាងឯកសារ
## ស្តីពី ទេសន្តរប្រវេសន៍ នៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃចន្ទ ប្រាំបួនកើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.ពីរពាន់ប្រាំរយហុកសិបប្រាំពីរ ត្រូវនឹងថ្ងៃទីដប់ប្រាំបី ខែមីនា ឆ្នាំពីរពាន់ម្ភៃបួន វេលាម៉ោងប្រាំបី និងសាមសិបនាទីព្រឹក នៅសណ្ឋាគារ SUNWAY មានបើកកិច្ចប្រជុំ កម្រិតបច្ចេកទេស លើសេចក្តីព្រាងឯកសារ ស្តីពី ទេសន្តរប្រវេសន៍ នៃព្រះរាជាណាចក្រកម្ពុជា រៀបចំសម្រប សម្រួលដោយ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចូលរួមសហការពីអង្គការទេសន្តរប្រវេសន៍ អន្តរជាតិ (IOM) កិច្ចប្រជុំត្រូវបានដំណើរការបើកក្រោមអធិបតីភាព **ឯកឧត្តម ហ៊ូ ខុឡារី** **រដ្ឋលេខាធិការក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** ដោយមានការអញ្ជើញចូលរួមពី៖

១.លោកជំទាវ ឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ

២.លោកស្រី **គ្រីស្ទីន ផាកូ** ប្រធានបេសកកម្មអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM)

៣.ឯកឧត្តម ឧត្តមសេនីយ៍ឯក **សុខ សុមនា** អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍

៤.លោក **ជ័យ រដ្ឋា** អគ្គនាយករង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

៥.លោកស្រី **ស៊ឹម ផាណុំ** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន

៦.លោកឧត្តមសេនីយ៍ទោ **វ៉ែន មុន្នីរ័ត្ន** នាយករងទីចាត់ការ ការងារព្រំដែន ក្រសួងការពារជាតិ

៧.លោកឧត្តមសេនីយ៍ទោ **រស់ សុខធឿន** អនុប្រធាននាយកដ្ឋានការពារព្រំដែនទឹក ក្រសួងមហាផ្ទៃ

៨.លោកឧត្តមសេនីយ៍ត្រី **ដួង ស៊ីហៃ** អនុប្រធាននាយកដ្ឋានការពារព្រំដែនគោក ក្រសួងមហាផ្ទៃ

៩.លោក **ប៉ូ ច័ន្ទមុនី** អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ

១០.លោក **ថូ គុយរ៉ុង** អនុប្រធាននាយកដ្ឋានលិខិតឆ្លងដែន នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

១១.លោក **TYRONE APOLINAR** អ្នកជំនាញគ្រប់គ្រងទិន្នន័យអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM)

១២.លោក **នោ បណ្ឌូល** តំណាងក្រសួងកិច្ចការនារី

ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័ន និងក្រុមការងារបច្ចេកទេស សរុបចំនួន **៣១ រូប ស្រី ១០ រូប ។**

កិច្ចប្រជុំនេះមានគោលបំណង ដើម្បីបង្កើតសំណុំរបាយការណ៍ ស្តីពីទេសន្តរប្រវេសន៍នៅកម្ពុជា ដែលមាន ទិន្នន័យសុក្រឹត និងមានការបែងចែកតាមប្រភេទជាមូលដ្ឋាន សម្រាប់ប្រើប្រាស់ក្នុងគោលបំណងបង្កើតកម្មវិធី គោលនយោបាយ និងដំណោះស្រាយផ្តោតលើភស្តុតាងពាក់ព័ន្ធនឹងបញ្ហាទេសន្តរប្រវេសន៍ដូចជា ការធ្វើអន្តោប្រវេសន៍ ការធ្វើនីប្រវេសន៍ ការធ្វើទេសន្តរប្រវេសន៍វិលត្រឡប់ ប្រាក់បញ្ញើ ការធ្វើទេសន្តរប្រវេសន៍ការងារ និងការធ្វើ

ទេសន្តរប្រវេសន៍មិនប្រក្រតី។ ទិន្នន័យមូលដ្ឋានដែលបញ្ចូលក្នុងសំណុំរបាយការណ៍ ស្តីពីទេសន្តរប្រវេសន៍នៅកម្ពុជានេះរួមមាន និន្នាការទីផ្សារការងារ ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច បរិស្ថាន និងសង្គម នៃទេសន្តរប្រវេសន៍ ការចំណាយលើសេវាផ្ទេរប្រាក់ បញ្ហាសុខភាព ការអប់រំ មុខរបរ ស្ថានភាព នៃការរស់នៅ និងការងារ ប្រាក់ឈ្នួល ព្រមទាំងតម្រូវការរបស់ជនទេសន្តរប្រវេសន៍។

**លោកស្រី គ្រីស្ទីន ផាកូ** ប្រធានបេសកកម្មអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) មានមតិស្វាគមន៍ចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះ ។ លោកស្រី បានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជា គឺជាប្រទេសមួយដែលមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានការទាក់ទងជាមួយ Global Compact លើការងារទេន្តរប្រវេសន៍សម្រាប់បន្តអនុវត្តគោលនយោបាយអទិភាពទាំងបីរបស់ Global Compact ពាក់ព័ន្ធការធ្វើចំណាកស្រុកដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដែលសព្វថ្ងៃបាន និងកំពុងធ្វើសេចក្តីព្រាងក្នុងការប្រមូលធាតុចូលសម្រាប់អនុវត្តឲ្យបានត្រឹមត្រូវ ។ ថ្ងៃនេះផងដែរ គឺជាការជួបប្រជុំលើកទី១ សម្រាប់កម្រិតបច្ចេកទេសដែលបានចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការពិភាក្សាលើសេចក្តីព្រាង ស្តីពីទេសន្តរប្រវេសន៍ នៃព្រះរាជាណាចក្រកម្ពុជា ដែលនឹងទទួលបាននូវធាតុចូលល្អៗក្នុងការសម្រេចជាចុងក្រោយ ។ លោកស្រី បានបញ្ជាក់ជូនអង្គប្រជុំថា របាយការណ៍ទេសន្តរប្រវេសន៍ ពិតជាមានសារៈសំខាន់ណាស់ និងជាឧបករណ៍សម្រាប់កសាងសមត្ថភាព ដែលប្រទេសនីមួយៗត្រូវបានរៀបចំឡើងដោយខ្លួនឯងសម្រាប់ធ្វើការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធផ្សេងទៀត និងសម្រាប់ប្រើប្រាស់ឲ្យមានភាពស៊ីចង្វាក់គ្នាស្របតាមគោលនយោបាយ ដោយផ្អែកលើភស្តុតាង និងបញ្ជ្រាបនូវរាល់បញ្ហានីប្រវេសន៍ចូលទៅក្នុងផែនការអភិវឌ្ឍន៍ ។ របាយការណ៍ទេសន្តរប្រវេសន៍ បានផ្តល់នូវក្របខ័ណ្ឌមួយដែលមានការពាក់ព័ន្ធជាមួយប្រទេសមួយចំនួន ក្នុងការសហការតាមដានចំពោះការធ្វើទេសន្តរប្រវេសន៍របស់ប្រជាជន តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ និងកិច្ចព្រមព្រៀងនានា ដែលធ្វើឲ្យយើងងាយស្រួលក្នុងការតាមដានពាក់ព័ន្ធការអភិវឌ្ឍ និងការប៉ាន់ប្រមាណទៅលើសេដ្ឋកិច្ច ក៏ដូចជាផលប៉ះពាល់សង្គម ។ លោកស្រី បានលើកឡើងថា យើងទាំងអស់គ្នាបានដឹងហើយថា ប្រទេសកម្ពុជាមានពលករចំណាកស្រុកចំនួន ១,៣ លាននាក់ ហើយយើងពុំបានធ្វើការបែងចែកឲ្យបានច្បាស់លាស់ថា តើមានប៉ុន្មាននាក់ទៅស្របច្បាប់ ប៉ុន្មាននាក់ទៅមិនស្របច្បាប់ មានឯកសារគ្រប់គ្រាន់ដែរឬទេ? និងមានសុវត្ថិភាពឬអត់? ចំពោះរបាយការណ៍ទេសន្តរប្រវេសន៍ដែលយើងលើកយកមកបង្ហាញក្នុងថ្ងៃនេះ គឺមានការពាក់ព័ន្ធការគ្រប់គ្រងទិន្នន័យទេសន្តរប្រវេសន៍ និងនិន្នាការ ក៏ដូចជាគោលនយោបាយសំខាន់ៗមួយចំនួនទៀត របាយការណ៍នេះគាំទ្រដោយមូលនិធិអង្គការទេសន្តរប្រវេសន៍អន្តរជាតិ ហើយសង្ឃឹមថា របាយការណ៍នេះនឹងត្រូវបានរៀបចំឲ្យបានពេញលេញតាមរយៈការផ្តល់ធាតុចូលសំខាន់ៗពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការផ្សព្វផ្សាយ និងប្រើប្រាស់ក្នុងខែមេសា ឆ្នាំ២០២៤ ខាងមុខនេះ ។

**លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណា សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ មានមតិស្វាគមន៍ចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះ ដោយ លោកជំទាវ បានលើកឡើងថា កិច្ចប្រជុំក្នុងថ្ងៃនេះ គឺដើម្បីប្រមូលធាតុចូលសំខាន់ៗទៅក្នុងឯកសារព្រាង ស្តីពីទេសន្តរប្រវេសន៍ នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់អនុវត្តក្នុងការគ្រប់គ្រងទិន្នន័យជនទេសន្តរប្រវេសន៍ទាំងស្របច្បាប់ និងមិនស្របច្បាប់ ដោយយើងបានផ្តោតទៅលើ ៤ ចំណុចសំខាន់ៗ ១.និន្នាការ

ទេសន្តរប្រវេសន៍ និងលក្ខណៈ នៃជនទេសន្តរប្រវេសន៍ ២.ផលប៉ះពាល់ នៃទេសន្តរប្រវេសន៍លើវិស័យអភិវឌ្ឍន៍នានា ៣.អភិបាលកិច្ចទេសន្តរប្រវេសន៍ ៤.របកកំហើញសំខាន់ៗ និងផ្នែកពាក់ព័ន្ធ នៃគោលនយោបាយ និងអនុសាសន៍ ។ លោកជំទាវ បានមានមតិថ្លែងអំណរគុណចំពោះអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM|) ដែលបានសហការគាំទ្រក្នុងការចូលរួមចំណែកយ៉ាងសកម្ម ជាមួយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ហើយថ្ងៃនេះផងដែរក៏បានសហការបើកកិច្ចប្រជុំកម្រិតបច្ចេកទេស លើសេចក្តីព្រាងឯកសារ ស្តីពីទេសន្តរប្រវេសន៍ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ សង្ឃឹមថាយើងនឹងទទួលបានផ្លែផ្កាគួរជាទីពេញចិត្ត ។

**ឯកឧត្តម ហ៊ូ ឌុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានមានប្រសាសន៍លើកឡើងពាក់ព័ន្ធនឹងសេចក្តីព្រាងឯកសារ ស្តីពីទេសន្តរប្រវេសន៍នៅកម្ពុជា គឺជារបាយការណ៍មួយដ៏មានសារៈសំខាន់ក្នុងការយកទៅអនុវត្តឲ្យមានប្រសិទ្ធភាព ប៉ុន្តែអ្វីដែលជាចំណុចស្នូល នៃរបាយការណ៍នេះ គឺការគ្រប់គ្រងទិន្នន័យការប្រមូលទិន្នន័យទេសន្តរប្រវេសន៍ ទើបយើងធ្វើការងារនេះបានល្អប្រសើរ ។ ឯកឧត្តម បានលើកឡើងអំពីការប្រើប្រាស់ពាក្យបច្ចេកទេស (ខ្មែរ អង់គ្លេស) សូមផ្តោតលើខ្លឹមសារ អត្ថន័យ ធ្វើយ៉ាងណាប្រើពាក្យខ្លីតែមានន័យវែង និងស៊ីជម្រៅ គ្រប់គ្រាន់ក្នុងការស្តាប់ និងយល់ ពីអ្នកប្រើប្រាស់ និងអ្នកអនុវត្តផ្ទាល់ ។ ឯកឧត្តម មានប្រសាសន៍បន្តថា ការប្រមូលទិន្នន័យពីតាមបណ្តាក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា ក៏មិនទាន់មានភាពច្បាស់លាស់ និងសុក្រឹតដែរ សូមឲ្យមានការចូលរួមពីជំនាញ នៃវិទ្យាស្ថានជាតិស្ថិតិ ដើម្បីចូលរួមធ្វើការងារគ្រប់គ្រងទេសន្តរប្រវេសន៍ ពីព្រោះពួកគាត់មានជំនាញជាមួយការងារស្ថិតិនេះ ។ ឯកឧត្តម មានប្រសាសន៍ថ្លែងអំណរគុណចំពោះអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ដែលបានផ្តួចផ្តើមបង្កើតសេចក្តីព្រាងឯកសារ ស្តីពីទេសន្តរប្រវេសន៍ នៃព្រះរាជាណាចក្រកម្ពុជា នេះឡើង និងបានសហការគាំទ្រដល់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) និងសូមអរគុណចំពោះការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ។

**លោក** TYRONE APOLINAR ៖ Data Specialist អង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM) ឡើងធ្វើបទបង្ហាញ ស្តីពីទេសន្តរប្រវេសន៍ នៃព្រះរាជាណាចក្រកម្ពុជា ដោយ លោក បានធ្វើការបកស្រាយពន្យល់ជូនអង្គប្រជុំ អំពីចំណុចសំខាន់ៗក្នុងឯកសារដែលបានចែកជូន ។

ពាក់ព័ន្ធនឹង Slide ទី៣ ដែលបានលើកឡើងថា (ប្រភពទិន្នន័យក្នុងប្រទេស)

**លោកជំទាវ ឧត្តមសេនីយ៍ឯក ម៉ុណ្ណា សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ ស្នើសុំឲ្យមានបន្ថែមអគ្គស្នងការដ្ឋាន អគ្គនាយដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកដ្ឋានរដ្ឋបាល នាយកដ្ឋានការពារព្រំដែនគោក នាយកដ្ឋានការពារព្រំដែនទឹក ចំណុះក្រសួងមហាផ្ទៃ និងបន្ថែមទីចាត់ការការពារព្រំដែន នៃអគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស ចំពោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ជាស្ថាប័នមួយដែលមាន ២២ក្រសួង និង៥អង្គភាពចំណុះ ដូច្នេះត្រូវដាក់នៅខាងលើ ហើយដាក់ក្រសួង ស្ថាប័នចំណុះនៅខាងក្រោម ចំពោះអង្គភាពមិនមែនជាសមាជិក គ.ជ.ប.ជ ដាក់ស្មើនឹង គ.ជ.ប.ជ។ **លោកជំទាវ** បានបន្តថាចំពោះ Slide ទី១៣ (ទិន្នន័យបន្ថែមចាំបាច់សម្រាប់របាយការណ៍ទេសន្តរប្រវេសន៍) ដែលបានដកស្រង់ទិន្នន័យរយៈពេល១០ឆ្នាំ (២០១២-២០២២) គឺមានរយៈពេលវែង សូមស្នើយកត្រឹមតួលេខ៥ឆ្នាំ

ចុងក្រោយបានហើយ (២០១៨-២០២៣) ។ លោកជំទាវ បានលើកឡើងអំពីការគ្រប់គ្រងពលករទេសន្តរប្រវេសន៍ជាប់គាំង ទាំងស្របច្បាប់ មិនស្របច្បាប់ បាត់ឯកសារ ឬមានបញ្ហាអីផ្សេងទៀត សូមក្រសួង ស្ថាប័ន បែងចែកឲ្យបានច្បាស់លាស់ ដូចកន្លងមកការបែងចែកជនរងគ្រោះ និងជនងាយរងគ្រោះ នៅមិនទាន់ធ្វើការកំណត់ឲ្យបានច្បាស់លាស់ ដូច្នេះបញ្ហានេះសូមឲ្យមានការបញ្ជាក់អំពីករណីជាប់គាំងមកពីមូលហេតុអីខ្លះ? ដែលបញ្ហានេះ គឺមានការពាក់ព័ន្ធនឹងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមរយៈស្ថានទូត ស្ថានអគ្គកុងស៊ុលប្រចាំនៅក្រៅប្រទេសគោលដៅ ដែលជាអ្នកជួយជនទេសន្តរប្រវេសន៍ទាំងអស់នេះ សូមញែកទិន្នន័យខាងលើដើម្បីងាយស្រួលក្នុងការអនុវត្តន៍ ។

**លោក តៀវ ខៃ** ប្រធានគម្រោង អង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM) ឡើងធ្វើបទបង្ហាញ(បន្ត) ស្តីពីទេសន្តរប្រវេសន៍ នៃព្រះរាជាណាចក្រកម្ពុជា ដោយ លោក បានធ្វើការបកស្រាយពន្យល់ជូនអង្គប្រជុំ អំពីចំណុចសំខាន់ៗក្នុងឯកសារដែលបានចែកជូន ។ លោក បានស្នើសុំ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័នផ្តល់ធាតុចូលពាក់ព័ន្ធទិន្នន័យទេសន្តរប្រវេសន៍ ទាំងកុមារ ស្ត្រី និងបុរស ដែលអាចឈានទៅរកការជួញដូរមនុស្ស ឬការកកស្ទះណាមួយនៅក្រៅប្រទេស បញ្ហានេះត្រូវគិតទាំងជនបរទេសចូលមកកម្ពុជា និងប្រជាជនកម្ពុជាចេញទៅក្រៅប្រទេស ជាពិសេសសំដៅលើជនអន្តោប្រវេសន៍ដែលគ្មានឯកសារត្រឹមត្រូវ ឬមិនប្រក្រតីដោយប្រការណាមួយ តើក្រសួង ស្ថាប័ន អង្គភាពណាខ្លះទទួលខុសត្រូវ ទទួលបន្ទុកលើបញ្ហាទាំងអស់នេះ?

**លោក នោ បណ្តូល** តំណាងក្រសួងកិច្ចការនារី បានលើកជាយោបល់ចូលរួមក្នុងកិច្ចប្រជុំទាក់ទងនឹង GPP ដែលកន្លងមកពលករយើងបានរងគ្រោះដោយអំពើជួញដូរមនុស្ស និងក៏ជាជនងាយរងគ្រោះផងដែរនោះ ក៏នៅមានជនរងគ្រោះដោយអំពើហឹង្សា ការរំលោភបំពានទាក់ទងនឹងយេនឌ័រ ដូច្នេះស្នើសុំឲ្យមានការបន្ថែមសូចនាករពាក់ព័ន្ធទេសន្តរប្រវេសន៍ជាស្ត្រី ក្នុងសេចក្តីព្រាងឯកសារ ស្តីពីទេសន្តរប្រវេសន៍ នៃព្រះរាជាណាចក្រកម្ពុជា នេះផង។

**លោកស្រី គ្រីស្ទីន ផាកូ** ប្រធានបេសកកម្មអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) បានលើកឡើងអំពីការគ្រប់គ្រង និងការប្រមូលទិន្នន័យថា តើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីឲ្យមានភាពច្បាស់លាស់ និងមានសុក្រឹតភាពចំពោះទេសន្តរប្រវេសន៍? សូមស្នើដល់ក្រសួង ស្ថាប័នពាក់ព័ន្ធធ្វើការកំណត់ឲ្យបានច្បាស់លាស់អំពីការធ្វើចំណាកស្រុករបស់ពលករដោយប្រក្រតី ស្របច្បាប់ និងរៀបរយ ប្រសិនបើការធ្វើចំណាកស្រុកមិនប្រក្រតី មិនស្របច្បាប់ តើមកពីមូលហេតុអ្វី? មកពីឯកសារ ឬមកពីការអនុវត្តរបស់មន្ត្រី ឬយ៉ាងណា?

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ចូលរួមក្នុងកិច្ចប្រជុំនេះថា ចំពោះទិន្នន័យភាគច្រើនយើងអាចរកបានពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប៉ុន្តែរបាយការណ៍មួយចំនួន គឺមិនមាននៅក្នុងដៃរបស់ក្រសួងការងារទេ គឺយើងទទួលបានពីក្រសួងការងារថៃ ពីព្រោះពាក្យថាពលករទេសន្តរប្រវេសន៍ មានន័យថា គឺជាការធ្វើចំណាកស្រុកទៅក្រៅប្រទេស បើយើងមិនអាចក្តាប់ទិន្នន័យអ្នកចេញ-ចូលមិនបានទេ នោះយើងក៏មិនអាចដឹងអំពីអ្នកជាប់គាំងបានដែរ នៅពេលដែលយើងមិនអាចគ្រប់គ្រងទិន្នន័យបាន វិធានការរបស់យើងក៏មិនអាចអនុវត្តបានល្អដែរ យើងត្រូវតែមានទិន្នន័យទើបយើងអាចគ្រប់គ្រងស្ថានការណ៍បាន បើមិនមានទិន្នន័យទេ យើងមិនមានសមត្ថភាពក្នុងការគ្រប់គ្រងបានទេ ត្រូវរកមធ្យោបាយដើម្បីដឹងថាទិន្នន័យទាំងអស់នេះមានប្រភពមកពីណា? ហើយតើលក្ខខណ្ឌបែបណាដែលចាត់ទុកថាជាទិន្នន័យត្រឹមត្រូវ និងអាចយកមកប្រៀបធៀបពីមួយឆ្នាំទៅមួយឆ្នាំដើម្បីឲ្យមានសុក្រឹតភាព ក្នុងការគ្រប់គ្រងទេសន្តរប្រវេសន៍ ។ លោកជំទាវ បានមានប្រសាសន៍លើកឡើងអំពីការប្រមូលទិន្នន័យក្នុង Slide ទី៣ ដែលបាន

លើកឡើងថា (ប្រភពទិន្នន័យក្នុងប្រទេស) ដោយដកស្រង់ពី សារព័ត៌មានភ្នំពេញប៉ុស្តិ៍ លោកជំទាវ បានសួរបញ្ជាក់ថា តើអាចជឿជាក់បានប៉ុណ្ណាដែលយករបាយការណ៍ពីសារព័ត៌មាន? ដូចករណីមានសារព័ត៌មានក្រៅប្រទេសបានសរសេរថា មានជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជាប់គាំងនៅកម្ពុជា ជាង១០ម៉ឺននាក់ ហើយ UNODC បានយករបាយការណ៍របស់សារព័ត៌មានមកធ្វើការផ្សព្វផ្សាយ ធ្វើឲ្យមានការយល់ច្រឡំ និងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វិស័យទេសចរណ៍ អ្នកវិនិយោគ សេដ្ឋកិច្ច ក៏ដូចជាកិត្តិយសរបស់កម្ពុជាផងដែរ ទីបំផុតគាត់មកជួបផ្ទាល់ បានត្រឹមនិយាយសូមទោសកម្ពុជាតែប៉ុណ្ណោះ អ្វីដែលសោកស្តាយ គឺបានកម្ពុជាខូចឈ្មោះទៅហើយ ដូច្នេះក្នុងនាមរដ្ឋាភិបាលក្តី អង្គការដៃគូ UN ក្តីមិនគួរយកទិន្នន័យពីសារព័ត៌មានឡើយ នៅក្នុងប្រភពទិន្នន័យដែលយើងទទួលបានខាងលើនេះ គួរបញ្ជូលក្រសួងព័ត៌មាន ពីព្រោះក្រសួងព័ត៌មាន គឺជាអ្នកទទួលខុសត្រូវលើការចេញផ្សាយរបស់សារព័ត៌មាននៅកម្ពុជា ។

**ឯកឧត្តម ហ៊ី ខុម្ភារី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានប្រសាសន៍ស្នើឲ្យមានការរៀបចំកិច្ចប្រជុំសេចក្តីព្រាងនេះជាបីជំហាន ដោយជំហាននីមួយៗអាស្រ័យលើលទ្ធផល នៃកិច្ចប្រជុំដែលទទួលបាន ជំហានទី១. កិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ(លើកជាមតិយោបល់ និងមានការឯកភាពអំពីដំណើរការ នៃគោលបំណងកិច្ចប្រជុំ ។ ជំហានទី២. កិច្ចប្រជុំកម្រិតបច្ចេកទេស គឺជាកិច្ចប្រជុំថ្នាក់ដឹកនាំជំនាញ នៃបណ្តាក្រសួងស្ថាប័ន អង្គភាពពាក់ព័ន្ធ ក្នុងការផ្តល់នូវធាតុចូលទៅតាមគោលបំណង នៃកិច្ចប្រជុំ រហូតសម្រេចបាននូវលទ្ធផលចុងក្រោយច្បាស់លាស់ ដើម្បីសុំសេចក្តីសម្រេចពីថ្នាក់ដឹកនាំ ។ ជំហានទី៣. កិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំ គឺជាកិច្ចប្រជុំប្រកាសផ្សព្វផ្សាយ និងដាក់ឲ្យអនុវត្តឲ្យមានប្រសិទ្ធភាព ។

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍បិទកិច្ចប្រជុំលើសេចក្តីព្រាងឯកសារ ស្តីពីទេសន្តរប្រវេសន៍ នៃព្រះរាជាណាចក្រកម្ពុជា ដោយលោកជំទាវ បានលើកឡើងថា កិច្ចប្រជុំពាក់ព័ន្ធបញ្ហានេះ គឺមិនអាចពិភាក្សាគ្នាត្រឹមមួយលើករួចរាល់នោះទេ ពីព្រោះបញ្ហានេះមានសារៈសំខាន់ណាស់ ក្នុងការធ្វើផែនការ ការដាក់យុទ្ធសាស្ត្រ គោលនយោបាយដែលគ្មានទិន្នន័យច្បាស់លាស់ទេ គឺយើងមិនអាចអនុវត្តបានដោយជោគជ័យដែរ អស់រយៈពេលជាង ២០ឆ្នាំហើយដែលយើងបានធ្វើការងារផ្នែកទេសន្តរប្រវេសន៍ តើទទួលបានជោគជ័យដែរទេ? គឺមិនទទួលបានជោគជ័យទេ ពីព្រោះយើងមិនមានទិន្នន័យច្បាស់លាស់ និងត្រឹមត្រូវ នោះយើងមិនអាចធ្វើការឆ្លើយតបចមចំណុចបានទេ ដូច្នេះពីពេលនេះទៅមុខយើងនឹងធ្វើឲ្យបាន ជាពិសេសនៅក្នុងនីតិកាលទី៧ នៃរាជរដ្ឋាភិបាល ស្របពេលដែលយើងកំពុងតែរៀបចំផែនការយុទ្ធសាស្ត្រជាតិ ២០២៤-២០២៨ គិតថាគឺជាពេលវាលាសមស្របណាស់ដែលយើងត្រូវធ្វើការកែលម្អនូវអ្វីដែលយើងមាន និងចំណុចខ្វះខាតតាមរយៈការឆ្លងកាត់បទពិសោធន៍រាប់សិបឆ្នាំកន្លងមក ។ **លោកជំទាវ** មានប្រសាសន៍ឯកភាពក្នុងការបង្កើតផែនការជាក់លាក់ ដោយផ្អែកលើទិន្នន័យ ចំពោះទិន្នន័យយើងនាំគ្នារកពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ បើនៅមានចំណុចខ្វះខាតយើងបន្ថែមទៀត បញ្ហានេះនៅមានការចូលរួមពីក្រសួង ស្ថាប័ន អង្គភាពមួយចំនួនទៀត ។ ក្នុងនាម គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដើរតយ៉ាងសំខាន់នៅក្នុងថ្នាក់ជាតិ និងអន្តរជាតិ ដោយយើងធ្វើការប្តេជ្ញាចិត្តក្នុងការធ្វើឲ្យកម្ពុជាក្លាយជាប្រទេសជ័យលាភីមួយក្នុងចំណោមប្រទេសជាង ១០០នៅលើពិភពលោក ក្នុងឆ្នាំ ២០២៥ យើងនឹងធ្វើឲ្យបានចំពោះទិន្នន័យដើម្បីបង្ហាញគេ ថាតើយើងធ្វើបានអ្វីខ្លះ? ហើយសង្ឃឹមថាក្រសួង ស្ថាប័នទាងអស់នឹងធ្វើបាន សូមពិនិត្យឡើងវិញ និងខិតខំប្រមូលទិន្នន័យពាក់ព័ន្ធឲ្យបានគ្រប់ជ្រុងជ្រោយ យើងមិនត្រូវពឹងផ្អែកលើគេបន្តទៀតដែរ យើងត្រូវ

ច្បាស់លាស់ខ្លួនយើង ការលំបាកប្រាកដជាមាន ប៉ុន្តែត្រូវមានកិច្ចសហការ ហើយយើងក៏ចង់ដឹងថាប្រទេសគោលដៅ និងប្រទេសទទួលាមានកិច្ចសហការជាមួយប្រទេសយើងប៉ុណ្ណា? ពីព្រោះមិនមែនតែកម្ពុជាទេដែលទទួលខុសត្រូវលើបញ្ហានេះ គឺជាបញ្ហារួមគ្នាគ្រប់បណ្តាប្រទេសទាំងអស់ ។ **លោកជំទាវ** មានប្រសាសន៍កោតសរសើរដល់ អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ដែលបានខិតខំបន្តកិច្ចសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស យើងនឹងត្រូវធ្វើការពិភាក្សាបន្តទៀតសង្ឃឹមថាគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងចូលរួមជាមួយគ្នាបន្តទៀតដើម្បីពិភាក្សាលើការងារនេះ ត្រូវមានការយល់គ្នា និងធ្វើឲ្យសម្រេចបាននូវលទ្ធផលល្អ ដើម្បីប្រទេសជាតិយើង ប្រជាជនយើង ក៏ដូចជាស្នាដៃរបស់ផងដែរ ។

**លោកជំទាវ** មានប្រសាសន៍ថ្លែងអំណរគុណចំពោះការចូលរួមរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធដែលបានអញ្ជើញចូលរួមកិច្ចប្រជុំក្នុងថ្ងៃនេះ និងសូមថ្លែងអំណរគុណដល់ អង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ដែលតែងគាំទ្រសហការរហូតមក។ សូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី មានសុខ សុវត្ថិភាព ជោគជ័យគ្រប់ភារកិច្ច និងជួបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

កិច្ចប្រជុំកម្រិតបច្ចេកទេស លើសេចក្តីព្រាងឯកសារ ស្តីពីទេសន្តរប្រវេសន៍ នៃព្រះរាជាចក្រកម្ពុជា ត្រូវបានបញ្ចប់នៅវេលាម៉ោង ដប់មួយ និងហាសិបនាទី ថ្ងៃខែឆ្នាំដដែល ។

ថ្ងៃពុធ ១១កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤

**អ្នកធ្វើកំណត់ហេតុ**

វរសេនីយ៍ឯក **សៅ ស៊ីនួន**

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ០៣ ឆ្នាំ២០២៤

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.**ប៊ុណ្ណា សំខាន់**

បានឃើញ
21/03/24